សៀវភៅគតិលោក

ភាគទី៧



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

CHANBOKEO.COM
ឆែន បន្ទុំអេង

រឿងមេឆ្កែខ្មោចអសុព

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានមេសុនខ១ នាំកូនទៅស្វែងរកអាហារបរិភោគលុះទៅដល់ព្រៃទីបាឆាមួយបានឃើញសាកសពខ្មោចកំពុងហើម គេចោលនៅទីប៉ាឆានោះ មេសុនខក៏នាំកូនចូលទៅ ទើបកូនសួរទៅមេថា ម៉ែៗនេះគេហៅអ្វីៗ?។ មេសុនខក៏ប្រាប់ថា "រូបនេះគឺខ្មោចមនុស្សណោកូនគេយកមកចោលនៅទីនេះ"។ កូនឆ្កែឮមេប្រាប់ជាខ្មោចមនុស្សដូច្នោះ ក៏កើតចំណង់ចង់ស៊ីខ្មោចនោះ ទើបថា "ម៉ែ ខ្ញុំចង់ស៊ីភ្នែកវាជាមុន"។ មេហាមថា "ភ្នែកជាកម្លាំងច្រៃណាស់ ឯងស៊ីវាមិនបានទេណាកូនកូន"។ កូនឆ្កែសួរថា "ម្តេចម៉ែឯងថាភ្នែកជាកម្លាំងច្រៃដូច្នោះហះ"។

មេឆ្កែប្រាប់ថា "ភ្នែកនេះកាលវាទស់នៅ វាតែងសម្លឹងសម្លក់មើលនូវទ្រូបបានម្ល៉ាំផ្ទេរឯៗ មានរូបស្ត្រីដើម ភ្នែកនេះកាលបើវាយល់រូបល្អ រូបគាប់ចិត្តហើយវានាំចិត្តឲ្យប្រាថ្នាលោភចង់បានរូបនោះ។ បើពុំបានវានាំចិត្តឲ្យសៅសោកក្តៅក្រហាយបណ្តាលឲ្យហ៊ានធ្វើនូវអំពើបាបលាមកមានព្យាបាទជាដើម ហេតុនេះទើបថាភ្នែកនេះ ជាកម្លាំងច្រៃក្រៃពេកណាស់

កូនឯងកុំស៊ីភ្នែកនោះទៀយ"។ កូនឆ្កែបានស្តាប់មេអធិប្បាយទោសភ្នែកដូច្នោះហើយ ទើបថា "បើដូច្នោះខ្ញុំនឹងស៊ីត្រចៀកវិញចុះ"។ មេឆ្កែក៏ហាមថា "ត្រចៀកនេះក៏ជាកម្លាំងច្រៃដូចគ្នា គឺកាលវាទស់នៅនោះវាចង់ស្តាប់សព្ទសម្តែងទាំងឮមានសម្លេងស្ត្រីតូរ្យតន្ត្រីជាដើម ត្រចៀកនេះវានាំកាយឲ្យត្រាប់ដើរស្តាប់សព្ទសម្តែងទាំងពួង សម្លេងណាពីនោះវានាំចិត្តឲ្យសោមនស្សត្រេកអរ សម្លេងណាវិញគ្រាតមិនពីនោះ ឬឮសម្លេងអ្នកដែលជាសត្រូវនឹងខ្លួន វានាំចិត្តឲ្យទោមនស្សខាត់ខឹង ចងអាឃាដព្យាបាទទៀងហេតុនោះ ទើបថា ត្រចៀកនេះជាអាយតន:កាម្លាំងច្រៃក្នុងលោកនេះ មិនគួរកូននឹងវាទៀយ"។ កូនឆ្កែថា "បើដូច្នោះខ្ញុំស៊ីច្រមុះវិញចុះ"។ មេឆ្កែក៏ហាមថា "ច្រមុះក៏ជាកម្លាំងដូចគ្នា គឺកាលវាទស់នៅនោះវាចង់ចើបចង់ស្រូបហិតក្លិនផ្សែង ក្លិនឯណាក្រអូបវានាំចិត្តឲ្យប្រាថ្នា ក្លិនឯណាស្អុយឆ្អាបឆ្អេះ វានាំចិត្តឲ្យក្តៅក្រហាយណាយស្អប់ខ្ពើមឆ្អែមហេតុនោះទើបថាច្រមុះនេះជាអាយតន:កាម្លាំង មិនគប្បីកូនចង់ស៊ីវាទៀយ"។ កូនឆ្កែក៏ថា ដូច្នោះខ្ញុំនឹងស៊ីមាត់ សុអណ្តាតជាបានឬមិនបានណាម៉ែ?។ មេឆ្កែក៏ហាមទៀតថា "មាត់នឹង

អណ្តាតជាកម្បុកណ្តើចត្រែលើសលែងឯងទៀតមាត់នេះកាលនៅទស់នោះ ទាំនិយាយមុសាកុហកគេ ទាំជេរពោលប្រទេចផ្តាសាគេ ទាំញុះញង់ស្តីបំបាក់បំបែកគេ ទាំស្តីដើមពោលបង្កាច់បង្កិនគេជាដើមយ៉ាងនេះ ឯអណ្តាតនោះសោត ក៏ជាអាយតនៈពាល់ត្រូវទំតែរសជាតិមាហារ ទាំប្រាថ្នាតែវត្ថុឆ្ងាញ់ពីសា បើបានពាល់ត្រូវទំរសឆ្ងាញ់ពីរបស់ណាហើយ ទាំនាំចិត្តឲ្យប្រាថ្នាចង់បានទៀយទៀត បើពាល់ត្រូវទំលើរសមិនឆ្ងាញ់ពីសាកាលណា ទាំនាំចិត្តឲ្យក្តៅក្រហល់ក្រហាយទៅផ្សេងៗ ហេតុនេះទើបថាមាត់អណ្តាតនេះជាអាយតនៈកាម្បុកណ្តើ មិនគប្បីស៊ុទាំទៀយ"។ កូនឆ្កែថា "បើដូច្នោះខ្ញុំនឹងស៊ុដែទិញយ៉ាងនេះតើគួរឬម្តេច?។ មេឆ្កែក៏ហាមទិញទៀតថា "ដែក៏ស៊ុមិនបានដូចគ្នា ដែនេះកាលទាំទស់នៅនោះទាំតែងចាប់ដំបងព្រនង់ត្រើងសស្រ្តាវុធប្រហារទាំយចាក់កាច់សម្លាប់មនុស្ស ជួនណាទាំឆក់យកទ្រព្យសម្បត្តិគេនានា នាំរូបទាំឲ្យបានក្តីទុក្ខជាប់គុកជាប់តារាងខ្លោះឃ្លាងទៅផ្សេងៗ ហេតុនោះទើបថាដែនេះជាកាម្បុកណ្តើចត្រែលើសគេ មិនគួរនឹងបរិភោគទាំទៀយ"។ កូនឆ្កែថា "បើដូច្នោះខ្ញុំនឹងបរិភោគដើងទាំចុះ"។ មេឆ្កែក៏ហាមទៀតថា "ដើងក៏ជា

កាម្បុកណ្តើដូចគ្នាកាលទាំទស់នៅ ដើងនោះសោតទាំនាំរូបដើនត្រាច់ចរទៅលេងទៅមើលទៅស្តាប់ទៅលួចទៅប្លន់គេ ជួនកាលទាំដើនទៅជាន់លាមកជាន់បន្លា ជាន់លើកម្រាលអាសនៈព្រះភិក្ខុសង្ឃជាទីមិនគួរជាន់ ជួនណាទាំដើនទៅជាន់ដើងចោរនាំឲ្យគេដឹតចិត្តសង្ស័យថាខ្លួនជាចោរជាអ្នកដើនយប់គប់ពាលសាមាន្យ បានក្តីទុក្ខទោសក្នុងលោកិយ ហេតុនេះទើបថាដើងនេះជាមហាចត្រែកាម្បុកណ្តើ មិនគួរគប្បីបរិភោគទាំទៀយ"។ កូនឆ្កែថា "បើដូច្នោះខ្ញុំនឹងស៊ុពោះពុងទិញ"។ មេឆ្កែហាមទៀតថាពោះពុងនោះជាលំនៅនៃចិត្តៗ នោះហៅមនោសរនេះជាអាយតនៈទទួលធម្មារម្មណ៍ នាំតាមតំនឹតដែលតឹតតឹ តឹតចង់បានទ្រព្យសម្បត្តិ ប្រាថ្នាយសសក្តិជាត្រើងលោកិយ តាមក្តីវត្ថុកាមកិលេសតាម តឹតចង់ឈ្នះគេ តឹតឈ្នានីសគេ តឹតលុបគុណគេ តឹតមាក់ងាយគេ តឹតព្យាបាទគេ តឹតមាយាបិទទោសឯងសំដែងទោសគេ តឹតសម្លឹងចង់បានទ្រព្យសម្បត្តិគេ តឹតែប្រយោជន៍ឯងមិនបែងប្រយោជន៍ដល់អ្នកដទៃផង ចិត្តតឹតក្នុងការអកុសលយ៉ាងនេះ ទើបថាពោះពុងជាលំនៅនៃចិត្ត ពោះពុងនេះជាកាម្បុកណ្តើចត្រែត្រែពេកណាស់កូនឯងនឹងស៊ុទាំពុំបាន ចូរខានទៅ

ចុះកូនកុំស៊ីចំណីកាឡកណ្ណីនេះទៀយ"។

កូនឆ្កែបានស្តាប់មេអធិប្បាយ អំពីចំណីកាឡកណ្ណីដូច្នោះហើយ ក៏ជឿតាមពុំបានគិតចង់ស៊ីខ្មោចនោះតទៅទៀត ហើយនាំគ្នាវិលទៅកាន់លំនៅនៃអាត្មាវិញហោង។

ទៀងនេះ បានគតិដល់បុគ្គលអ្នកពិចារណាឲ្យឃើញថា អវិយទ:តូចធំសម្រាប់រូបកាយនេះជាកាឡកណ្ណី តើតដោយក្តីប្រមាទមិន ឱហាតបង្អាត់អវិយទ: ឲ្យដំកល់នៅក្នុងការស្វែងរកមង្គល បុគ្គលអ្នកនក្ខាអវិយទ:មិនឲ្យធ្លាក់ចុះជាកាឡកណ្ណីនោះ គឺកាន់តែន្ត្រីយសំវិនវិលី នក្ខាទ្វារទាំង៦ មានចក្ខុទ្វារជាដើម មិនឲ្យបាបធម៌ចូលទៅបៀតបៀនចិត្តខាងក្នុងបាន សង្រួមកាយមិនឲ្យបាបធម៌ចូលពាល់ត្រូវបាន ប្រដៅកាយឲ្យឆ្ងាយអំពីអកុសលកម្ម គឺកាយកម្ម៣ វិចីកម្ម៤ មនោកម្ម៣ ដែលហៅថាអកុសលកម្មបថទាំង១០ នោះឯង ឯសេចក្តីសង្រួមទ្វារទាំង៦ និងការតាំងនៅក្នុងកុសលកម្មបថ១០ នោះក្នុងតំរានេះមិនបានសំដែងឲ្យពិស្តារទេ មាននៅក្នុងកំរាគតិធម៌ឯណោះហើយ ចូរទៅមើលយកជាគតិចុះ។

បុគ្គលនក្ខាត្តន្ត្រីយ ៦ ទៀរអកុសលកម្មបថ១០ នោះបាន

ឈ្មោះហៅថាធ្វើអវិយទ:ឲ្យផុតចាកកាឡកណ្ណីចន្ត្រែ ដូចនិយាយដែលមេសុនខសំដែងប្រាប់កូនទាំនោះឯង អញ្ចឹញ្ញអ្នកប្រាជ្ញគតិទៅទៀតចុះ។

ចប់តម្រាអវិយវ:កាឡកណ្ណីទី ៣៥។

ទៀងនាយដង្កៀនឹងកូនឈ្លូ

មាននាយដង្កៀម្នាក់ ទៅជួញបានចំណេញមកមានក្តីសប្បាយចិត្ត គិតនឹងលៀងអស់បណ្តាមហាជនជាញាតិមិត្តក្នុងលំនៅនៃអាត្មា ទើបប្រើបោយឲ្យទៅផ្ទះនាទិញ្ញម្ហូបចំណីហើយផ្តាំថា "ចូរទៅឯងទិញត្រីទិញសាច់ទើសនកតែល្អៗ យកមកឲ្យយើងធ្វើម្ហូបលៀងពួកញាតិមិត្តដែលនៅជិតនេះឲ្យសប្បាយម្តង"។

ឯចៅបោយក៏ទទួលពាក្យនាយ យកប្រាក់អំពីនាយស្តាយត្រកដើរទៅផ្ទះនាធំ លុះទៅដល់ផ្ទះនាចៅបោយគិតថា នាយអញ្ញគាត់ផ្តាំថាឲ្យទិញសាច់អណ្តាតសត្វចុះ សាច់អណ្តាតនោះល្អហើយគិតហើយចៅបោយទិញសុទ្ធតែអណ្តាតសត្វទាំងឡាយមានអណ្តាតគោជាដើម បានហើយក៏ដោតជាត្រណោតយួរមកដល់ផ្ទះជូននាយដង្កៀនោះ។ នាយដង្កៀយល់អណ្តាតសត្វដូច្នោះហើយក៏ស្តីបន្ទោសទៅថា "យើងឲ្យទៅទិញយកសាច់ល្អៗចុះ

ហេតុអ្វីចៅទិញយកតែអណ្តាតគោ អណ្តាតជ្រូក អណ្តាតពពែ
មកដូច្នេះនេះហើយឬជាសាច់ល្អ?។ ចៅបាយក៏អធិប្បាយថា
"សាច់អណ្តាតនេះហើយលោកនាយ ដែលជាសាច់ល្អលើសសាច់
ទាំងពួងបានជាខ្ញុំបាទថាល្អនោះ ព្រោះខ្ញុំយល់ថា លោកអ្នកបាន
យសបានសក្តិ បានមាស បានប្រាក់ បានខ្ញុំកំដរ បានជាមេជាបា
គេក្នុងលោកនេះ សឹងអាស្រ័យបានដោយអណ្តាតក្រលៀស
ពោលទៀង ហេតុនេះទើបលោកសន្មតថាអណ្តាតនេះជាសាច់
ល្អលើសលែងសាច់នានា បានជាខ្ញុំបាទទិញយកមកនេះ"។
នាយដង្កៀបានឮចៅបាយឆ្លើយតបដោយទៀហានដូច្នោះក៏
ទាល់សេចក្តីមិនអាចថាអ្វីតទៅទៀតទៀយ បានក្តីខ្មាសនឹង
ពាក្យចៅបាយទៅទិញសាច់ម្តងទៀត បានផ្តាំថា ចូរទិញ
យកសាច់អាក្រក់ៗមកចុះ យើងនឹងធ្វើម្ហូបលេងភ្លៀវ។

ចៅបាយទទួលប្រាក់ទទួលពាក្យហើយក៏ទៅផ្ទះ ដល់
ហើយក៏ទិញអណ្តាតសត្វដូចកាលមុនបានហើយ ក៏នាំយកមកជូន
នាយដង្កៀ។ យល់អណ្តាតសត្វដូចមុនដូច្នោះ ក៏ស្តីបន្ទោសថា
ពីមុនលិញយើងឲ្យទៅទិញសាច់ល្អ។ ចៅឯងទិញយកអណ្តា
តសត្វមក ហើយពោលថាអណ្តាតនេះហើយ ជាសាច់ល្អលើស

លែងសាច់ឯទៀតៗ ៗ ថ្ងៃនេះយើងផ្តាំថាឲ្យទិញសាច់
អាក្រក់។ ហេតុអ្វីក៏ចៅទិញអណ្តាតសត្វដែលចៅអួតថាសាច់
ល្អនោះមកទៀត។

ចៅបាយក៏ឆ្លើយកែសំនួនថា "សាច់អណ្តាតនេះហើយលោក
នាយ ដែលជាសាច់អាក្រក់លើសលែងសាច់ឯទៀតៗ បានជាខ្ញុំ
បាទថាអាក្រក់នោះ ព្រោះអណ្តាតនេះឯងទាក្រលៀវទាក្រលៀ
សពោលបង្កាច់បង្កិនគេ ស្នះតិះដៀល ជេរប្រទេច ផ្តាសា ស្តីម្រ
សា កុហកបញ្ឆោតបញ្ឆោតគេ ញុះញង់ស៊ូកសៀត បំបែកបំ
បាក់គេទៅដៀងៗ ហេតុនេះឯងទើបលោកសន្មតថាអណ្តាត
នេះជាសាច់អាក្រក់លើសលែងសាច់នានាក្នុងលោកិយនេះ បាន
ជាខ្ញុំបាទទិញមកតាមប្រសាសន៍ដែលលោកនាយផ្តាំ ថាឲ្យទិញ
សាច់អាក្រក់នោះឯង។ នាយដង្កៀ បានស្តាប់ពាក្យចៅបាយ
ពោលដូច្នោះក៏ទាល់សេចក្តី ពុំអាចថាអ្វីទៅទៀតបាន ដោយ
អាត្មាចាញ់ប្រាជ្ញាចៅបាយ ដោយប្រការដូច្នេះហោង។

ទៀងនេះ បានគតិដល់បុគ្គលដែលធ្វើជានាយចៅហ្វាយឬជា
ត្រូវអាចារ្យមេបាគេ កាលនឹងប្រើបាទប្រើសិស្សឲ្យទៅយកអ្វី
។ គប្បីបញ្ជក់ពាក្យបណ្តាំឲ្យអ្នកបំទើនោះស្តាប់ចូលចិត្ត

សេចក្តីឲ្យបានច្បាស់ ទើបការនោះមិនប្រែខ្វែងទៅបាន។

មួយទៀត ជាតិអ្នកតូចនឹងទទួលពាក្យបណ្តាំអ្នកធំនោះ ច្រែនតែនរហ័យហួស ស្តាប់មិនទាន់ដាក់ប្រញាប់តែមិតនត់ទៅ មិនដឹងជាយកអ្វីហៅនរណាឲ្យទៅ ម្ល៉ោះហើយប្រមាណយកផ្តេសផ្តាសទៅ មិនត្រូវនឹងពាក្យបណ្តាំលោក ដូចយ៉ាងកូនសិស្សលោកព្រះមហាវិមលធម្ម ឈ្មោះចៅឡងលោកគ្រូប្រើឲ្យសួរទកចិត្តមូលភ្លឺដនឹងលោកអាចារ្យអួង ចៅឡងស្តាប់មិនច្បាស់ ក៏នត់ទៅដល់ផ្ទះម៉ាស៊ុនទឹកកក នឹងមើលក្រែងភ្លឺងឆេះផ្ទះ លុះពុំឃើញមានអ្វី ក៏ទីលមកទូលលោកវិញថា ភ្លើងម៉ាស៊ុទឹកកក មិនមានឆេះផ្ទះគេទេ។

លោកគ្រូបានឮដូច្នោះ ក៏ថាអញឲ្យសួរលោកអាចារ្យអួង ជាលោកមានចិត្តមូលភ្លឺឬទេ បើលោកមាន ឲ្យសុំលោកបន្តិចមកនឹងធ្វើថ្នាំ ចុះហេតុអ្វីក៏ចៅទៅដល់ផ្ទះម៉ាស៊ុនទឹកកកហើយថាភ្លើងឆេះផ្ទះអាណាគេប្រើឯងឲ្យទៅមើលភ្លើងឆេះផ្ទះ នោះចៅឯងជាមនុស្សស្តាប់ការគេមិនដាក់ មិនសួរសព្វឲ្យច្បាស់ចិត្តសិន លោកព្រះមហាវិមលធម្មក៏បន្ទោសចៅនោះដោយប្រការផ្សេងៗហោង។

មានទៀងចៅម្នាក់ទៀត ឈ្មោះសោមចៅនោះជាកូនសិស្សលោកសម្តេចព្រះសុគន្ធាធិបតី ថ្ងៃមួយមានពួកទាយកអ្នកមុខអ្នកការ គេមកថ្វាយទានដល់លោកៗប្រើចៅនោះថា "ចូរទៅយកពានមួយមកដើម្បីនឹងដាក់ស្លាបារី ចែកពួកទាយកអាស្រ័យ"។ ឯចៅនោះស្តាប់សព្ទមិនច្បាស់ ក៏ផ្តាសចេញទៅលីពាងទឹកមួយចូលមកនាកណ្តាលជំនុំប្រជុំជនធ្ងន់ណាស់ក៏ទូលថា "សូមមេត្តាប្រោសដាក់ត្រង់ណាពាងនេះ"។ ឯមហាជនទាំងឡាយមានលោកសម្តេចព្រះសុគន្ធាធិបតីជាប្រធាន ក៏សើចកងរំពងទៀងថា ចៅនេះជាមនុស្សទ្រអិលសហួសជ្រួសសេចក្តី គេប្រើឲ្យយកពាន ពុំមានសបសួរឲ្យដាក់ច្បាស់ ផ្តាសទៅយកឯពាងទឹកមកវិញ បានក្តីអៀនខ្មាសនាកណ្តាលជំនុំហោង។ មួយទៀតលោកអ្នកធំប្រើថ្លែងសព្ទមិនអស់ចុងអស់ដើម ពាក្យសព្ទនោះជួនស្របគ្នា អ្នកបំរើស្តាប់បានហើយ តែចង់បង្កាច់ឲ្យខុសវិញ ក៏បាននឹងបន្ទោសអ្នកបំរើវិញពុំបាន ដូចនិទានចៅវាយគងមានទំនងសព្ទស្របគ្នានោះឯង នឹងសំដែងឲ្យចូលចិត្តទៀងច្រឡំសព្ទនោះថា:៖

ទៀងបុរសចេះវាយគង

មានឱបាសកម្នាក់ក្នុងជនបទមួយគឺតបំបួសកូនក្នុងខែបឋមាសាធ បានទៅនិយាយដួលភ្លេងពិណពាទ្យគេជាដាច់ខាតលុះដល់ថ្ងៃចូលវេងប្រជុំជាតិនឹងចំនើនពុទ្ធមន្តហៅព្រលឹងនាគនោះ ពួកអ្នកភ្លេងនាំគ្រឿងភ្លេងចូលមកគ្រប់គ្នាទាំងអស់ តែអ្នកចេះវាយគងមកពុំបាន ព្រោះប្រពន្ធឆ្លងទន្លេ ផ្តាំតែពាក្យមកនឹងអ្នកភ្លេងផងគ្នាថា ឲ្យជំនាបអ្នកដឹមបុណ្យផងថា មកពុំបានទេព្រោះប្រពន្ធឆ្លងទន្លេឲ្យអ្នកដឹមបុណ្យគឺតវកដួលគេងទៀតចុះ។

ឯអ្នកដឹមបុណ្យនឹងបណ្តាមហាជនទាំងឡាយបានឮថាអ្នកវាយគងនោះ ទានពុំបានមកដូច្នោះក៏ប្រជុំពិគ្រោះគ្នាថា នឹងទៅវកដួលមនុស្សចេះវាយគងថាស ចៅនោះពិគ្រោះទៅវកពុំបាន ព្រោះស្រុកក្រៅមនុស្សចេះភ្លេងមានតិចនាក់ហើយពេលនោះក៏ជួនល្ងាចណាស់ហើយ នឹងទៅវកអ្នកចេះឯណាៗក៏ពុំទាន់ម្តោះហើយ ពួកអ្នកធ្វើបុណ្យទាំងនោះ ពុំសូវនឹកនាយសប្បាយព្រោះមិនពេញក្តីប្រាថ្នានៃអាត្មាទីទៃៗ។

គ្រាកាលនោះ មានអាម្នាក់មានឈ្មោះពុំប្រាកដសន្មតហៅ ចៅប្តូមបាយបុណ្យចៅនោះដើរទៅដល់យល់វេងគេធ្វើបុណ្យក៏

គិតថា អ្នកស្រុកនេះគេធ្វើបុណ្យ គួរអញ្ជើចូលទៅប្រចុបប្រចែងយកបាយចំណីបានស្កាអាស្រ័យ គិតហើយក៏ចូលទៅក្នុងវេងបុណ្យអង្គុយនៅទីដ៏គួរ សួរគេថា "អ្នកបងអ្នកប្អូនអើយ! ចុះគេធ្វើបុណ្យអីនេះអ្នក?។ ពួកអ្នកវេងប្រាប់ថា "គេធ្វើបុណ្យបំបួសនាគណាអ្នក"។ "ចុះអ្នកឯងមកពីស្រុកណាទៅណា?។ ចៅនោះក៏ប្រាប់ថា "ខ្ញុំមកពីក្រុងភ្នំពេញនឹងទៅសួរបងប្អូនឯស្រុកលើ ចុះខ្ញុំឮគេអោយពិគ្រោះគ្នាអ៊ូៗនោះ តែគេពិគ្រោះពីវេងអ្វី?។ ពួកអ្នកវេងប្រាប់ថា "ឱអ្នកអើយ ការបុណ្យនេះបានទៅ និយាយដួលភ្លេងពិណពាទ្យ គេជាការស្រេចហើយឥឡូវចូលវេងថ្ងៃនេះ ស្រាប់តែអ្នកដែលវាយគងគ្នាមានធុនៈដោយប្រពន្ធឆ្លងទន្លេមកពុំរួច ហេតុនោះទើបគេនាំគ្នាពិគ្រោះឆោទ្បា ដឹមឮនឹងវកអ្នកចេះវាយគង អើអ្នកអត់ទោសចុះខ្លួនអ្នកនេះតើចេះវាយគងដែរឬ?។ ចៅនោះក៏ទទួលថា "ក្រអ្វីសព្វបើវាយគងនោះ ឯងក៏ចេះវាយបាន"។ ឯពួកអ្នកវេងបានឮពាក្យចៅនោះថាចេះដូច្នោះ ក៏ត្រេអរគឹកកងឡើងប្រាប់គ្នាថា "អ្នកវាយគងនោះបានហើយ"។ ខ្លះសួរថា"អ្នកយកថ្លៃប៉ុន្មានក្នុងវេងបុណ្យនេះ"។

ចៅនោះថា "ខ្ញុំបាទយកកំលាំងចូលចាប់កុសលផង ត្រង់ថ្លៃថ្នូរនោះខ្ញុំមិនយកទេ សូមទានតែបាយចំណីអាស្រ័យជាកំលាំងចុះ"។

អ្នកដើមបុណ្យឮដូច្នោះ ក៏ត្រេអរពេញចិត្តដោយគិតថាសមភ័ព្វប្រាថ្នា ទើបទៀបបាយចំណីស្លាបារី អញ្ជើញចៅនោះបរិភោគតាមក្តីនាប់អាន ចៅនោះបានបរិភោគបាយចំណីបរិបូណ៌លុះសូទេចក៏ច្ចុបាយហើយ អ្នកដើមបុណ្យក៏ថាអញ្ជើញអ្នកទៅឯទីភ្លែង ដ្បិតពេលនេះល្មមហ៊ុំនាងហើយ។ ចៅនោះក៏ស្រែទាយកស្លាបារីអំពីដើងពាន់ ដាក់ថ្នក់ដាក់ហោប៉ៅអាវ ហើយក្រោកដើរទៅជាមួយ នឹងអ្នកដើមបុណ្យ។ នាំទៅដល់ក៏ប្រាប់ពួកអ្នកភ្លែងថា ខ្ញុំបានអ្នកទាយគងហើយ ចូរកុំមានក្តីនង្កៀសអ្វីទៀយដោយពុំមែនទង់ជាមួយគ្នា សូមមេត្តាលេងយកតែបុណ្យទៅត្រង់ពីនោះ មិនពីនោះនោះ គ្មាននរណាថាអ្វីទេ។ ឯអ្នកភ្លែងទាំង៨នាក់ក៏ព្រមតាមអធ្យាស្រ័យ ទើបថាអញ្ជើញអ្នកចូលមកចុះ ឯអ្នកដើមបុណ្យអញ្ជើញអ្នកចូលក្នុងទង់គងនេះចុះ។

ឯចៅនោះបែរមើលនាយមើលអាយហើយលើកដៃទៀងថា "ខ្ញុំបាទចេះតែទាយគងធំៗ ឮមួងៗ នោះទេត្រងគងទង់នេះខ្ញុំមិនចេះទេ"។

ឯបណ្តាមហាជនទាំងឡាយបានឮពាក្យចៅនោះថាដូច្នោះក៏សើចកងរំពងទៀង អ្នកខ្លះនឹងលួចជេរថា ខ្មោចអាចម្រែកោងឆយកបាយមួយថាសស៊ីតែម្តង ថាទាចេះទាយគងឯងនឹកស្មានថាទាចេះទាយគងភ្លែងនេះ ឥឡូវទាថាចេះទាយតែគងមួងៗមួយៗ នោះទីញ្ញាអាណាត្រូវទីការអីនឹងទាយគងមួងនោះតែក្មួនក្មេងក៏ចេះទាយបានទួទៅទាំងស្រុក ឱពុទ្ធោអើយពួកយើងនេះចាញ់កលនេះជាម្តង ឯអ្នកដើមបុណ្យក៏ថា ណ្លើយចុះការនេះឯងសួរដេញគេមិនរស់ចុងរស់ដើម គេក៏គេចប្រែទៅបានយ៉ាងនេះ នឹងបន្ទោសឬនឹងអូសយកបាយចំណីទីញ្ញាឯណាក៏បានតីក្តីខុសមាននៅលើខ្លួនឯងតែម្តង ថាហើយអ្នកដើមបុណ្យក៏ឲ្យអ្នកភ្លែង៨ នាក់លេងភ្លែងតាមទំនៀមទៅហោង។

អ្នកធំក៏ខូច អ្នកតូចក៏ខ្ចិល រំកិលផ្តុតបន្ទោសហេតុនោះនឹងប្រើត្រូវប្រយ័ត្នសព្វស្រប កុំឲ្យអ្នកតូចទាប្រកបគេចកែប្រែទៅបាន។

ចប់តម្រោគតិរប្រើមិនអស់ការទី ៣៦។

រឿងបុរសអាពុកនឹងកូននាំលាទៅលក់

មានបុរសម្នាក់ ឈ្មោះចៅខែកនឹងកូនប្រុសគាត់ម្នាក់ បានចិញ្ចឹមកូនលា១ ជាសត្វពាហន: លុះកូនលានោះចំរើនធំទៀង ប្រកបទ្រូបធាត់ល្អ ចៅអាពុកនឹងកូនពិគ្រោះគ្នាថា លាយើងធាត់ធំល្អហើយ បើនាំទៅលក់ឲ្យគេ ក្នុងសម័យនេះ យល់ជានឹងបានថ្លៃច្រើនព្រោះកំពុងធាត់ល្អ តែថានឹងដឹកនាំទៅដល់ស្រុកកំពង់ដែលមានគេត្រូវការទិញនោះឆ្ងាយណាស់ទម្រាំដល់ទៅលាយើងនេះ យល់ជានឹងស្គមប្រាកដ ដល់លក់មុខជានឹងថោកបានថ្លៃតិចមិនខាន បើដូច្នេះមានតែយើងគិតសែងវាទៅ កុំឲ្យវាដើរខ្លួនវាក្រែងស្គមទៅលក់មិនបានថ្លៃ។ អាពុកនឹងកូនគិតព្រមគ្នាហើយ ទើបចាប់លាមកចងជើងទាំង៤ យកឈើទែងសែកជាស្នែង នាំគ្នាសែងចេញចាកគ្រឹះស្ថាន លុះទៅដល់ទ្វារស្រុក ពួកអ្នកស្រុកបានឃើញអ្នកទាំងពីរសែងលាដូច្នោះ ក៏នាំគ្នាសើចកងរំពងទៀងហើយតិះដៀលថា "សត្វលាសត្វសេះនេះជាសត្វពាហន: គេតែងជិះតែងបរវា មិនដែលមាននរណាទៅលីទៅសែងវាដូចសត្វជ្រូកសត្វក្តាន់នោះទេ នេះហេតុអ្វីចៅអាពុកនឹងកូន មកនាំគ្នាសែងលា យ៉ាងនេះធ្វើឲ្យខុសគេក្នុងលោកិយនេះ នែចៅទាំងពីរចៅឯងឆ្កួតឬ បានជាមកសែងលាយ៉ាងនេះ ម៉េចក៏មិនជិះបរវាទៅ?។

ឯអាពុកនឹងកូន បានឮអ្នកស្រុកគេនាំគ្នាតិះដៀលខ្លួនដូច្នោះទើបពិគ្រោះគ្នាថា "យើងសែងលាវាខុសគេទៅហើយ បើដូច្នេះគួរស្រាយលាចេញគ្នាជិះបរទៅតាមពាក្យគេវិញចុះ តែនឹងជិះវាទាំងពីរនាក់មិនបាន ព្រោះកូនលានៅតូចក្រែងយោងទៅពុំរួច" គិតគ្នាដូច្នោះហើយចៅអាពុកក៏ថា "ណ្ហើយចុះខ្លួនអញនឹងដើរពីក្រោយ ចូរកូនឯងជិះបរវាទៅចុះឯចៅកូនក៏ទទួលតាមពាក្យអាពុក ហើយទៀងជិះលានោះបរទៅហោង។

លុះបរទៅដល់ភូមិស្រុកមួយ ពួកអ្នកស្រុកបានឃើញចៅលក់លាមកដល់ ក៏សួរទៅថា "អ្នកឯងជិះបរលានេះនឹងទៅឯណា?។ ឯអាពុកនឹងកូនប្រាប់ថា "ជិះបរនាំទៅលក់ឯស្រុកកំពង់ឯនោះ"។ អ្នកស្រុកក៏សួរទៅទិញថា" តាដែលស្ពាយទែងដើរពីរខាងក្រោយលានេះ តើគាត់ជាអ្វីនឹងចៅឯងដែលជិះលានេះ"។

ចៅកូនក៏ប្រាប់ទៅថា "គាត់ជាអាពុកខ្ញុំឯងនេះអ្នកសួរមានការអ្វីឬ?។ ឯពួកអ្នកស្រុកបានឮចៅនោះប្រាប់ថាអាពុកដូច្នោះក៏នាំគ្នាស្តីឆ្នះតិះដៀលថា "ចៅនេះជាមនុស្សមិនស្គាល់គុណបិតា

ខ្លួនគួរឬខ្លួនជាកូនជិះលាធ្វើអាការជានាយ ឲ្យអាពុកស្ពាយទៃ ដើរក្រោយដូចជាខ្ញុំកំដរខ្លួនយ៉ាងនេះ ខ្លួនឯងក្មេង គួរតែដើរស្ពាយទៃ ឲ្យអាពុកគាត់ជិះវិញនោះទើបគួរ ព្រោះគាត់ចាស់ជាងខ្លួនផង ជាបិតាខ្លួនផង វិ័យចៅកំទ្បោះឯងជិះនោះមិនត្រូវទេ ចូរចុះចេញពីខ្នងលាឲ្យឆាប់ឲ្យតាចាស់ជាអាពុកឯង ជិះវិញទើបត្រូវទំល្អ ។ ឯចៅអាពុកនឹងកូនបានឮពាក្យពួកអ្នកស្រុកតិះដៀលដូច្នោះហើយក៏ថា យើងធ្វើនេះត្រូវតែនឹងគ្នាហើយ បើដូច្នេះគួរអាពុកទ្បើងជិះវិញចុះ កូននឹងដើរមុខនាំផ្លូវទៅវិញ កាលបើគិតព្រមព្រៀងគ្នាហើយ ចៅកូនក៏ចុះពីខ្នងលា យកសំពាយទៃពីបិតាស្ពាយដើរមុខ ចៅអាពុកក៏ទ្បើងជិះលាបរចរទៅតាមមាគ៌ាឆ្ពោះ ស្រុកកំពង់នោះហោង ។

លុះបរទៅដល់អណ្តូងទឹក នៅចុងស្រុកមួយមានពួកស្រីក្រមុំទាំងឡាយវានាំគ្នាដងទឹកអណ្តូងនោះវាបានឃើញចៅកំទ្បោះទ្បល្អដើរមុខលា ឃើញតាចាស់ជិះលាបរដល់មក វាក៏នាំគ្នាមើលដោយជាតិស្រីក្រមុំគាប់ចិត្តតែនឹងកំទ្បោះ ត្រង់មនុស្សចាស់ដរានោះ ពុំគាប់ចិត្តទ្បើយ ហើយវានាំគ្នាតិះដៀលតាចាស់នោះថា "កូនលាធាត់ល្អណាស់ សមគួរតែអ្នកកំទ្បោះដែល

ដើរមុខនោះជិះវិញទើបល្អ នេះទ្យតាកញ្ជ្រស់មុខស្រមូមដូចស្វាខ្ចីជិះ យ៉ាងនេះហៅពេញអាក្រក់ក្រៃពេកណាស់ នែតាកញ្ជ្រស់អើយ! ចុះចេញទៅកុំជិះមិនសមល្អទេ មើលទៅដូចពានរជិះលា ចូរឲ្យអ្នកកំទ្បោះគេជិះវិញ ទើបគាប់ភ្នែកយើង ព្រោះរូបលាក៏ល្អត្រូវនឹងអ្នកកំទ្បោះល្អដូចគ្នា" ។

ឯចៅកូនបានឮស្រីក្រមុំថាដូច្នោះ ក៏បែរទៅនិយាយនឹងអាពុកថា "ឱអើយ ឥទ្ធរិទាខ្ញុសទៅទ្យើតហើយ គឺពួកមេអស់នេះទាត្រុះតិះដៀលខ្ញុំឯងថា ដូចជាពានរជិះលា ហើយវាថាឲ្យខ្ញុំជិះវិញទើបល្អយ៉ាងនេះ តើខ្ញុំនឹងគិតយ៉ាងណាទៅទ្យើត? ។

អាពុកតបថា "កាលមុនឯងជិះក៏ខ្ញុសម្តងទៅហើយ ដល់ឥទ្ធរិអញជិះក៏ខ្ញុសទៅទ្យើត បើដូច្នេះចូរកូនឯងទ្បើងមកជិះខាងមុខ ជាពីរនាក់នឹងអាពុកបរទៅទ្យើតហើយ ជាមិនគាប់ចិត្តមនុស្សពួកណាទៅមុខទ្យើត" ។

ឯចៅកូនក៏ទ្បើងជិះលាអង្គុយខាងមុខអាពុក បរលាឆ្ពោះទៅហោង លុះបរមកដល់ផ្ទះគយដែលតាំងនៅនាដើមផ្លូវ មេគយបែរមកឃើញអ្នកទាំងពីរជិះលា ក៏ចុះទៅសួរថា "អ្នកទាំងពីរជិះលានេះនឹងទៅឯណា" ។ ចៅអាពុកនឹងកូនប្រាប់ថា "នឹងទៅ

លក់លានេះឯស្រុកកំពង់ឯណោះ"។ មេគយក៏ត្មះតិះដៀលថា "កូនលានេះគ្នានៅស្មានទៀងស្មើនណាស់ ហេតុអ្វីចៅឯងប្រួតគ្នាជិះទាយ៉ាងថ្នាក់ឌឹង បើប្រួតគ្នាជិះម្ខឹងៗ តើគ្នានឹងធន់បោលបរទៅមុខបាន ទំនាំទៅដល់ស្រុកកំពង់លានេះ ឃើញជាបមបាក់កំទ្បាំងលក់ពុំបានចំណេញប្រាកដពុំខាន អ្នកឯងឆ្លតទេប្ឬ កូនលាគ្នានៅតូចហើយមកប្រួតជិះគ្នាយ៉ាងនេះ មុខមិនដឹកនាំទៅទីញ្ឃ?"។

ចៅអាពុកនឹងកូនបានឮមេគយបន្ទោសដូច្នោះក៏ចុះពីខ្នងលានាំគ្នាដឹកបណ្តើរលានោះ ឆ្ពោះទៅកាន់ស្រុកកំពង់នោះហោង។

លុះមកដល់ទីព្រៃចំការមួយ ពុំមានផ្លូវនឹងដឹកទៅទៀបអាពុកនឹងកូន នាំគ្នាដឹកលាដើរកាត់ចំការ ដែលគេមិនទាន់ធ្វើស្រែចដើរកាត់រកផ្លូវនឹងទៅទៀត អ្នកាប់ចំការបានឃើញចៅទាំងពីរ ដឹកលាដើរកាត់ចំការដូច្នោះ ក៏ស្រែកទៅថា "នែអ្នកដឹកលាទំចំការយើងនេះ យើងមិនទាន់កាប់គាស់ ដុតរំលីងឲ្យស្អាតទេ សឹងប្រកបដោយបន្លាដំឡូងខ្យា បន្លាឃ្លួ បន្លាឫស្សីជាដើម អ្នកដើរទៅមកតោងប្រយ័ត្នបន្លាទាំមុតអើរូបអ្នកឯង មានលាជាពាហន:សម្រាប់ជិះ មុខទៀយមិនជិះទា ទៅនាំគ្នាដឹកទាទីញ្ឃ

អ្នកឯងឆ្លតទេប្ឬ មានលាហើយមិនជិះស៊ូដឹកដើរឲ្យបន្លាមុតដូច្នេះ នែអ្នកដឹកលាអើយ! ចូរនាំគ្នាទៀងជិះទាទៅទុកទាធ្វើស្តេចអើ លាសេះគេតែងតែជិះទាជាធម្មតានៅនាលោកិយនេះឯង"។

ចៅអាពុកនឹងកូនបានឮអ្នកចំការតិះដៀលដូច្នោះក៏បែរមកនិយាយគ្នាថា "យើងផ្តាប់ចិត្តមនុស្សលោកិយនេះមិនបានទេ កាលដើមយើងនាំគ្នាសែងនោះគេនិន្ទាម្តងទៅហើយដល់ក្រោយឲ្យកូនជិះក៏ត្រូវគេនិន្ទាថាឯងមិនដឹងគុណអាពុក ដល់ក្រោយឲ្យអាពុកជិះវិញ ត្រូវគេមើលក្រមុំទាមិនគាប់ចិត្តនឹងតាចាស់ទានាំគ្នានិន្ទាផ្សេងៗ ដល់ក្រោយទៀងជិះទាំងពីរនាមេគយ ត្រូវគេមគយនិន្ទាថាលាស្មានទៀងជិះពីរនាក់មិនបាន ដល់ឡូវនេះ យើងដើរដឹកទាវិញ ក៏ត្រូវអ្នកចំការនេះនិន្ទាតិះដៀលថា មានលាហើយមុខចក៏មិនជិះអើតម្រាយ៉ាងនេះ តែរូបលាមួយនឹងផ្តាប់លោកិយមិនគាប់ទៅបាន"។

ទៀងនេះ បានតតិដល់បុគ្គលអ្នកតិតរកឱបាយកលឲ្យផុតអំពីពាក្យគេនិន្ទា តែទោះជាចេះយ៉ាងណាៗ ក៏ពុំមានឱកាសនឹងគេចឲ្យផុតពាក្យលោកិយទៅបាន មនុស្សក្នុងលោកិយនេះ

នរណានឹងទៅជាប់ឲ្យត្រូវចិត្តគ្រប់រូបបាននោះ គឺគាប់ឯណោះ
ខុសឯណោះយ៉ាងនេះ មានជាធម្មតា កុំថាយើងជាមនុស្សនឹង
មនុស្សផ្ទាប់គ្នាទៀយ ទោះទេវតាទេវបុត្រផុតវិស័យពីមនុស្ស
ក៏ផ្ទាប់ពួកមនុស្សមិនត្រូវដូចគ្នា ដូចយ៉ាងសុវិយទេវបុត្ត គឺថ្ងៃ
នេះថ្លៃលិចមានជាប្រក្រតីសព្វថ្ងៃនេះ ទៀលព្រឹកទៀងថ្ងៃនេះពី
ទិសខាងកើតមក លុះល្ងាចថ្ងៃលិចបាត់ពន្លឺទៅទិសខាងលិច
សុវិយគតិដើរស្មើដើរមានកំណត់ គឺមួយថ្ងៃ១២ ម៉ោងមួយយប់
១២ ម៉ោងដូចគ្នា យប់ថ្ងៃមានកំណត់យ៉ាងនេះ នៅផ្ទាប់ចិត្ត
មនុស្សក្នុងលោកិយនេះមិនត្រូវទៀ គង់មានពួកខ្លះថា ថ្ងៃនេះ យប់
នេះម្តេចយូរម្ល៉ះ ម្តេចឆាប់ម្ល៉ះ ម្តេចក្តៅម្ល៉ះ ម្តេចត្រជាក់
ម្ល៉ះ ពោលតិះដៀលយ៉ាងនេះជាដើម ក៏ឯយប់នឹងថ្ងៃមិនគាប់
ចិត្តមនុស្សនោះ ព្រោះមនុស្សនោះមានប្រាថ្នាចង់ឆាប់ចង់យូរ
ដោយចិត្តខ្លួនឯង ដូចយ៉ាងមនុស្សណាដែលត្រូវទោសលោកឲ្យ
ដាក់គុក តែងកំណត់ថាអ្នកឯងនៅ១០ ថ្ងៃឬ១ខែទៀត នឹងរួច
ចាកទោសនេះ មនុស្សនោះចង់រួចឆាប់ ទន្ទឹងដល់ខែដល់ថ្ងៃ
នឹងរួច ក៏តាំងរាប់ តាំងគិតទៅ ការដែលរាប់ដែលគិតនោះ ថា
ថ្ងៃអ្វីក៏យូរម្ល៉ះ ខែអ្វីក៏យូរម្ល៉ះ ពាក្យថាថ្ងៃយឺតយូរ ខែយឺត

យូរនោះ បានខាងមនុស្សដែលចង់រួចពីគុកនោះឯង។

មនុស្សពួកណា ជួលផ្ទះជួលទូកគេនៅលុះដល់ខែម្ចាស់គេទៅ
ទារប្រាក់ឈួល មនុស្សពួកនោះសឹងពោលថាថ្ងៃខែអ្វីក៏ឆាប់
ម្ល៉ះ រកតែនឹងឥតប្រាក់ម្តេចទាន់។ ពាក្យថាថ្ងៃខែឆាប់នោះ
បានខាងមនុស្សដែលជួលផ្ទះគេនៅនោះឯង។ ពាក្យអរស់នេះ
សមដោយបទបាលីក្នុងគម្ពីរលោកនីតិថា៖

ឥឃា ជាតរតោ រត្តិ
ឥឃំ សន្តស្ស យោជនំ
ឥឃោ ពាលាន សង្សារោ
សទ្ធម្មំ អវិជានតំ។

ប្រែថា យប់យូរនៃអ្នកគេងមិនលក់ឯង យោជនីយូរឆ្ងាយ
នឹងនៃអ្នកចរ សង្សារយូរឆ្ងាយនៃនិករ ពាលពុំចេះធម៌
ទៅនិញ្ញាន។

មួយទៀតលោកថា អ្នកដេកចង់ក្រោកថាយប់យូរ អ្នកដើរ
គិតគួរថាយោជនីឆ្ងាយ ពាលាពុំចេះធម៌ទាំងឡាយ សង្សារ
នឹងឆ្ងាយពីនិញ្ញាន។

ចប់តម្រោគតិផ្តាប់លោកមិនត្រូវទី ៣៧

រឿងចៅចាក់ស្មុគ

មានបុរសម្នាក់ហៅថា ចៅចាក់ស្មុកថ្ងៃមួយចៅនោះទៅដើរទៅលើចុងស្នោត តាំងកាត់ចៀរស្លឹកស្នោតចាក់ធ្វើជាស្មុតធំៗបានច្រែនហើយ ក៏ត្រៃអនប្រាឧព្ធចាប់បណ្តើរគិតបណ្តើរថា អញចាក់ស្មុតបានច្រែនហើយ អញយកទៅលក់ឲ្យគេអញ្ជឹបានប្រាក់១ ទៀល ទួចអញទៅទិញមេមាន់គេ បានមកចិញ្ចឹមទាំដល់ឃ្លូនទៅមេមាន់ ទាបង្កើតកូនសាយច្រែនទៀងហើយ អញលក់មាន់នោះឲ្យគេ អញបានប្រាក់៥ ទៀលហើយអញទៅទិញកូនជ្រូកគេមកចិញ្ចឹម លុះកូនជ្រូកនោះធំទៀង អញលក់ទៅទៀត បានប្រាក់១០ទៀល ហើយអញទៅទិញកូនគោ កូនសេះមកចិញ្ចឹម ដល់ទាំធំទៀងអញលក់ទៅទៀតបានប្រាក់កាន់តែច្រែនៗ ទៀងដល់មួយរយពីរយទៀល អញទិញស្រែទិញចំការ ទិញភូមិលំនៅៗ ជាសុខសប្បាយហើយ អញធ្វើស្រែបានស្រូវច្រែន អញលក់ស្រូវ លក់ផ្លែឈើបានប្រាក់ដល់បីរយបួនរយ អញដណ្តើងកូនក្រមុំគេយ៉ាងល្អ ធ្វើជាភរិយា ដល់នៅឃ្លូនទៅ អញមានកូនប្រុសមួយអញស្រឡាញ់ពេកណាស់អញលោះខ្ញុំស្រីម្នាក់ ឲ្យជាភីលៀងកូនអញកុំឲ្យ

ប្រពន្ធអញទាំពីបាកនឹងកូនចៅតទៅ ថាបើមេទាសីនោះ ទាបច្រពកូនអញមិនប្រយ័ត្ន ធ្វើឲ្យកូនអញដួលចុះ អញនឹងទះតប់ធាក់ក្បាលទាកុំឲ្យទាធ្លាប់។

ចៅនោះគិតក្តៀនសតិទៅដល់ធាក់ទាសី យានដើងធាក់ទៅលើធាងស្នោត ដោយពេញកំឡាំងក៏ធ្លាក់ចុះចាកចុងស្នោតនោះមួយរំពេច ចៅនោះមានស្មារតីស្រទាំចាប់ចុងស្លឹងស្នោតជាប់ព្យុនតែងតាង នឹងស្រទាំចាប់ធាងទៀងទៅទិញក៏ពុំរួច នឹងទម្លាក់ខ្លួនចុះមកដីខ្លាចក្តីស្លាប់ ព្រោះស្នោតនោះវែងខ្លាំ ចៅនោះក៏បានក្តីទុក្ខវេទនា ដោយតោងចុងស្លឹកស្នោតនោះឯង។

គ្រាកាលនោះមានទ្រមាក់ដំរីម្នាក់ បរដំរីមកត្រង់ដើមស្នោតនោះ ទើបចៅស្មុតស្រែកអង្វរទៅថា "ឱ! អ្នកបងអើយ! មេត្តាជួយយកអាយុខ្ញុំបានក្នុងគ្រានេះ ជួយដាក់ខ្ញុំបានផង បើខ្ញុំបាននូចអាយុម្តងនេះខ្ញុំនឹងទៅនៅជាខ្ញុំបំរើអ្នកបង"។ ឯទ្រមាក់ដំរីបានឃើញបានឮដូច្នោះ ក៏បរដំរីទៅខាងក្រោមដើមស្នោតហើយក្រោកឈរទៀងលើខ្នងដំរី ដើយទៅនឹងទម្លួចាប់ជើងចៅនោះ នៅពុំទាន់ស៊ប់ល្អក្នើនជើងជាន់ខ្នងដំរី ឯដំរីនឹងថាម្ចាស់ឲ្យដើរទៅ ទាក៏ដើរចេញអំពីទនោះទៅ ឯចៅទ្រ

មាក់ក៏ចាប់ជើងចៅចាក់ស្មុគនោះជាប់នៅតែងតោង ទើបស្រែអង្វរទៅចៅចាក់ស្មុគវិញថា "ចូរអ្នកចាប់ចុងស្លឹកត្នោតឲ្យជាប់កុំលែងដៃទៀយ បើខ្ញុំរួចជីវិតម្តងនេះ ខ្ញុំទទួលគុណអ្នកដាក់លើកក្បាលនឹងទៅជាខ្ញុំបំរើអ្នកហោ"។

ឯចៅចាក់ស្មុគឮដៃណាស់ក៏ស្រែកថា "ចូរលែងចាប់ជើងយើងទៅ យើងធ្ងន់ឮដៃណាស់ តែខំចាប់យ៉ាងនេះមុខជាស្លាប់ហើយ ចូរលែងចាប់ជើងយើងទៅ"។

ឯចៅទ្រមាក់ចេះតែអង្វរថា "សូមអ្នកមេត្តាចាប់ខាងលើឲ្យជាប់ ខ្ញុំមិនហ៊ានលែងដៃខ្ញុំពីជើងអ្នកទេក្រែងធ្លាក់ស្លាប់ធ្វើម្តេចជាគ្រោះកាចនាំឲ្យបានក្តីទុក្ខយ៉ាងនេះ"។

គ្រានោះមានចៅក្បាលទំពែក៤ នាក់នាំគ្នាទៅដឹកអញ្ចាំងធំ ដើរទៅត្រង់ចៅទាំងពីរនោះឯង ចៅទាំងពីរបានឃើញចៅទំពែកទាំង៤នាក់ ក៏ស្តីអង្វរថា "លោកអ៊ុំ លោកមាអើយ ជួយយកអាយុខ្ញុំបាទផង បើខ្ញុំបាទបានរួចជីវិតហើយ នឹងទៅនៅជាខ្ញុំបំរើលោក"។ ចៅទំពែកបួននាក់ឮដូច្នោះក៏ថា "យើងនឹងទៀងទៅជួយដាក់ឯណាបាន បើចៅនៅតែងតោងព្យួរនឹងចុងធាងស្មៅយ៉ាងនេះ"។

ចៅទាំងពីរក៏ថា "ឲ្យលោកអ៊ុំ លោកមាឈរកាន់កាងអញ្ចាំងជា ៤ មុមឲ្យជាប់ខ្ញុំបាទទាំងពីរនាក់នឹងលោតទៅក្នុងអញ្ចាំងនោះឯង"។

ឯចៅទំពែកទាំង៤ នាក់ក៏ធ្វើតាមទើបនាំគ្នាកាងអញ្ចាំងជា៤ជ្រុងហើយយកចុងខ្សែចងពីខ្នែកទៀងខ្លួនស្រែច ហើយក៏ហៅចៅទាំងពីរនាក់ឲ្យទំលាក់ខ្លួនចុះមក ចៅទាំងពីរក៏ទំលាក់ខ្លួនចុះទៅលើអញ្ចាំងព្រមគ្នាមួយរំពេច។

ឯអញ្ចាំងនោះ លុះត្រូវទម្ងន់ចៅពីរនាក់ ក៏ដូចជាគេកន្ត្រាក់រួបចូលគ្នាចៅទំពែក៤ នាក់ក៏ប្រទាញ់រួបដូចគេបោលចូលទង្គិចក្បាល នឹងក្បាលគ្នាឯងបែកខ្ចរខាងក្នុង ដួលចុះដល់មរណាកាលទាំងបួននាក់នៅក្រោមដើមស្មៅនោះហោង។

ឯចៅទាំងពីរនាក់បានរួចក្តីស្លាប់អំពីចុងស្មៅហើយបានឃើញចៅទំពែកទាំងបួនស្លាប់ដូច្នោះក៏និយាយគ្នាថា យើងបានរួចជីវិតនេះ ព្រោះតាទំពែកគាត់ជួយកាន់អញ្ចាំងដំទៀង ឲ្យយើងលោតមកសុទ្ធតែជាកម្មគាត់មកស្លាប់ទាំងអស់ ដូច្នេះយើងនឹងតបសងគុណយ៉ាងម៉េច បើយើងនឹងចាត់ចែងដុតដាវធ្វើឈាបនកិច្ចឆ្លងគុណគាត់ទៅ ក្រែងមេស្រុកចៅហ្វាយស្រុក គេដាក់ទោស

ឯងថាទាំយមនុស្សសម្លាប់គេនឹងចាប់ឯងទៅធ្វើទោស នឹងប្រាប់គេតាមត្រង់គេក៏ពុំជឿឯង ព្រោះពុំមានបន្ទាល់សាក្សីជាទីអាងជាការនាំឲ្យកើតទោស កើតទុក្ខទៅមុខទៀតបើដូច្នេះយើងនាំគ្នាកាយដីកប់សពគាត់ហើយ សូមខមាទោសនឹងគាត់ទៅចុះ។

ចៅទាំងពីរពីគ្រោះយល់ព្រមគ្នាហើយទើបកាយដីកបសពចៅទំពែកទាំង៤នោះ ហើយសំពះស្មាលាទោសតាមទំនៀមស្រែចហើយ ចៅទាំងពីរក៏លាគ្នាទៅកាន់លំនៅនៃអាត្មាទីទៃហោង។

ទៀងនេះ បានគតិដល់បុគ្គលអ្នកគិតវិតក្កតាមអារម្មណ៍នាំបណ្តែតទៅតាមអារម្មណ៍នោះ កើតភ្លើសតិ ភ្លេចស្មារតី ភ្លាត់ទៅទាំងកាយផង ឯចៅទ្រមាក់ដីរីបានសេចក្តីប្រមាទ ទៅទុកចិត្តសត្វតិរច្ឆានតីខ្លួនជាន់លើខ្នងដីរី ឈោងដៃទៅចាប់ជើងចៅចាក់ស្មុគជាន់មិនស៊ប់ ក៏ទ្រេតទ្រោតទៅមក ដីរីក៏នឹកសញ្ញាថាម្ចាស់ឲ្យដើរទៅ ទើបវាដើរចេញទៅ ខ្លួនក៏ចាប់ជើងចៅចាក់ស្មុគនោះជាប់ បានក្តីភិតភ័យនឹងក្តីស្លាប់មហិមា។

ឯសេចក្តីស្លាប់នេះ ជាសភាវៈបុគ្គលខ្លាចក្រែពេកណាស់ដូចចៅចាក់ស្មុគភ័យនឹងក្តីស្លាប់ ក៏ទទួលជាខ្មាំបំរើចៅទ្រមាក់ដីរីៗចង់បានគេជាខ្មាំដល់មិនសមក្តីប្រាថ្នា ក្តីភ័យនឹងមរណកាលដល់ខ្លួន

វិញក៏ត្រឡប់ទទួលខ្លួនជាខ្មាំអ្នកចាក់ស្មុគនោះវិញ ហេតុនោះបានគតិថា ក្តីមរណភ័យនេះតែមាននៅលើបុគ្គលណាហើយបុគ្គលនោះ អាចហ៊ានទទួលជាបាវជាខ្មាំគេបានទាំងអស់ ព្រោះក្តីស្រឡាញ់អ្វីៗមិនស្មើនឹងស្រឡាញ់ជីវិតនៃអាត្មាហោង ឯចៅទំពែកទាំងបួនជួយយកអាយុគេ ដោយឥតបញ្ញានឹងពិចារណាមើលទម្ងន់មនុស្សពីរនាក់ ដែលទំលាក់ចុះក្នុងអញ្ចងនោះខ្លួនឯងទ្របានឬពុំបាន ដល់ទ្រពុំបានដោយកំលាំងធ្ងន់ខ្សែអញ្ចងប្រទាញ្ចួបចូល ទាញ្ចូទាំងខ្លួនឲ្យដល់គ្នាបែកក្បាលស្លាប់ឯខ្លួនឯងវិញ ក្តីប្រាថ្នាពុំសុំទេចទៅបាន។

ក៏ឯចៅចាក់ស្មុគនោះ លុះក្តីតាមវិតក្តគឺភ្លើសតិភ្លាត់ដើងធាក់ធាងស្មោត ធាក់ទាំងខ្លួនបាននូវទុក្ខវេទនាដូចពណ៌នាមកនេះ គួរអ្នកប្រាជ្ញដឹងដោយទោសកាមវិតក្ក គឺពុំមានសតិដាស់តឿនខ្លួនទៀង។

មួយទៀត មានទៀងស្រីក្តីឆ្កួម្នាក់ ធ្លាក់ចិត្តគិតចុះក្នុងកាមវិតក្ក បានដល់នូវក្តីក្តៅក្រហាយចិត្តជាក្រោយ និទានោះមានសេចក្តីដូច្នេះ។

មានស្ត្រីម្នាក់ជាអ្នកក្រ ថ្ងៃមួយទៅទទួលទឹកដោះគោគេបាន

ហើយដាក់នឹងភ្នែមទូលដើរទៅ លុះដល់កណ្តាលផ្លូវនាងនោះគិត
តាមទឹតក្តគិតថា កាលណាអញទៅលក់ទឹកដោះនេះ បានប្រាក់
ច្រើនហើយអញនឹងទិញមេមាន់មេទាមកចិញ្ចឹម ដល់ឃ្លូនទៅ
មេមាន់មេទាបង្កើតកូនសាយច្រើនទៀង អញលក់បានថ្លៃ
ប្រមូលប្រាក់បានច្រើន អញនឹងទិញមេគោមេពពែមក
ចិញ្ចឹមឲ្យបានច្រើនទៀងអញធ្វើដង្កៀលក់ទឹកដោះ គិតជា
អ្នកមានធំ អញធ្វើផ្ទះថ្មពីនជាន់នៅ អញលោះខ្ញុំស្រី ខ្ញុំប្រុស
ប្រើក្នុងការអញជានាយដង្កៀអញលក់ក្នុងមួយព្រឹក។ បាន
ប្រាក់រាប់រយរាប់ពាន់ក្បាតិទាំងឡាយសឹងកោតខ្លាចអញទាំង
អស់ ដល់មានការធ្វើបុណ្យអ្វីៗ អញនឹងបរិច្ចាគទ្រព្យប្រដាប់
ការបុណ្យនោះឲ្យសប្បាយ អញដួលល្ងោនដួលភ្លេងមកលេង
ហើយអញក៏វាំងឲ្យគេមើលផង។

នាងនោះគិតបណ្តើរដើរបណ្តើរ ក៏ភ្លើសតិភ្លេចអាត្មាលើក
ដៃទាំងពីរនាំចាក់ក្បាច់លោតយ៉ាងទំនងក្បាច់ល្ងោនបាវាំង តាំង
ទេកទេខ្លួនទៅផ្សេងៗ ឯភ្នែមទឹកដោះដែលទូលលើក្បាលនោះ
ក៏ហក់ធ្លាក់ដល់ដីបែកកពប់ទឹកដោះអស់ម្តង ទើបនាងនោះដឹង
ខ្លួនថាខ្លួនគិតហួសគិតផ្តាស បង់ទឹកដោះអស់ដើមទុនក៏ស្តាយទឹក

ដោះនោះក្រែពន់ពេក ហើយក្តៅក្រហាយចិត្ត បន្ទោសខ្លួនឯង
ទៅផ្សេងៗហោង។

តម្រាក្តៅចិត្តឯងនេះ គិតដោយអំណាចគិតចង់បានវត្ថុកាម
កិលេសកាម ហៅថាកាមវិតក្តមែនពិតវិតក្តបីប្រការគឺ កាមវិ
តក្ត១ ព្យាបាទវិតក្ត១ វិហិង្សាវិតក្ត១ វិតក្ត៣ ប្រការនេះបើមាន
នៅលើរូបបុគ្គលណាហើយ នាំរូបបុគ្គលនោះឲ្យដល់នូវទុក្ខក្តៅ
ក្រហាយចិត្តក្នុងកាលក្រោយ ហើយជាទោគឲ្យគិតគេងពុំលក់
ស៊ីពុំពីសា ធ្វើកាយាឲ្យស្គាំស្គមទ្រុមចូលទៅក្នុងភ្លើងដ៏នាជាឆាប់
គួរចូលចិត្តចុះ។

មួយទៀត ការមិនគួរគិតហើយគិតនេះជាទីនាំចិត្តឲ្យទង្វែង
ឆ្ងាតទៅផ្សេងៗ អ្នកប្រាជ្ញលោកពោលទុកក្នុងគម្ពីរលោក
ន៏តិថាដូច្នេះ ៖

អបត្តេយ្យំ ន បត្តេយ្យ
អចិន្តេយ្យំ ន ចិន្តេយ្យ
សភាវមេវ ចិន្តេយ្យ
កាលំ មោឃំ អនិច្ចេយ្យ។

ប្រែថា កុំប្រាថ្នាការមិនគួរប្រាថ្នាបាន កុំគិតអានការមិនគួរ

បុគ្គលតិត គួរតិតតែការសភាពរបស់ពិត កុំប្រាថ្នាកុំទៅតិតការទទេៗ

ចប់តម្រាការវិតក្កទី ៣៨។

ទើរឿងសត្វហង្សនឹងអណ្តើក

មានហង្សមួយគូតែងនាំគ្នាទៅលេងទឹកស្រះ១ ជានិរន្តរ៍ បានយកអណ្តើកមួយជាសម្លាញ់ៗ ឯអណ្តើកនោះ តែហង្សមកលេងទឹកកាលណា ក៏ទាចេញមកនិយាយចរចាប្រស្រ័យជាមិត្រនឹងគ្នា លុះនៅយូរទៅ ស្រះនោះកើតរឹងហួតហែង អណ្តើកនឹងនៅពុំបាន ទើបនិយាយនឹងហង្សថា "សម្លាញ់អើយ! ខ្ញុំឯងនឹងនៅអាស្រ័យ ក្នុងស្រះនេះតទៅទៀតពុំបានទៀយព្រោះឥតទឹក ដូចសម្លាញ់ឃើញស្រាប់ហើយ"ៗ

ឯហង្សទាំងអស់ក៏ថា "បើដូច្នេះមានតែយើងនាំគ្នាទៅអាស្រ័យឯមហាបោក្ខរណីនៅខាងជើងព្រៃហិមពាន្តឯនោះទៅញុះ ដ្បិតស្រះនោះជ្រៅធំទូលាយសប្បាយ ទាំងផលាផលទាំងទ្បាយជាភក្ក្បាហារក៏បរិបូណ៌ គួរសម្លាញ់ឯងទៅនៅឯមហាស្រះនោះចុះ" ។ អណ្តើកឮហង្សថាដូច្នោះ ក៏តបថា "ខ្លួនខ្ញុំឯងជាសត្វដើរខ្លី លូនដោយផែនដី ធ្វើម្តេចនឹងទៅដល់មហាស្រះ

នោះបាន?ៗ

ហង្សទាំងគូក៏ថា "ការនាំសម្លាញ់ទៅកាន់មហាស្រះនោះជាភ្នាក់ងារយើងនាំទៅដោយផ្លូវទំអាកាស តែយើងខាំពាំឈើស្នែងឲ្យសម្លាញ់ឯងខាំ តោងពីក្រោមឲ្យជាប់យើងទាំងគូនឹងហើរនាំទៅ"ៗ

អណ្តើកបានស្តាប់ដូច្នោះ ក៏ព្រមតាមទើបហង្សទាំងគូទៅកាត់ឈើស្នែងបាន ក៏ពាំទាំងសងខាងឲ្យអណ្តើកខាំតោងពីក្រោម ហើយហង្សបានហាមអណ្តើកថា "ចូរសម្លាញ់ទកគ្រាមាត់ឲ្យជិតទោះទៅឃើញអ្វីៗក្តី ឬបានឮសព្ទអ្វីៗក្តី កុំបីហាមាត់សួរឬនិយាយពីអ្វីៗទៀយ ព្រោះការដើរដោយផ្លូវទំអាកាសនោះក្រលំបាកណាស់ តែភ្លាត់មាត់កាលណាក៏វិនាសក្នុងកាលនោះ ហេតុនោះចូរសម្លាញ់ប្រយ័ត្នមាត់កឲ្យមែនទែន"ៗ ហង្សទាំងពីរហាមប្រាមអណ្តើកស្រេចហើយ ក៏នាំគ្នាខាំពាំឈើខ្វែងជាបង្គងហើរហោះផ្លោះទៀងលើអាកាសទៅ មានភក្ត្រាតម្រង់ទៅឧត្តរទិសៗ

លុះមកដល់កណ្តាលនគរពារាណសី បណ្តាក្មេងទាំងឡាយ បានឃើញហង្សហើរពាំនាំអណ្តើកដូច្នោះ ទាក៏បង្កកហៅគ្នាតីកកង

រំពងទៀងទាំងស្រុកស្រែកប្រាប់គ្នាថា "ទុំយគ្នាយើង ឯងមើលហង្សវាពាំអណ្តើកនោះ យ៉ាងជាវាយកទៅស៊ុងលំនៅ ហើយឯង" ។

ឯអណ្តើកបានឮពាក្យកូនក្មេងថា ហង្សពាំនាំអណ្តើកយកទៅស៊ុដូច្នោះ ក៏ខឹងនឹងកូនក្មេង គិតថាអាក្មេងអស់នេះវាស្តីប្រមាថមាក់ងាយអញពេញទីជាម្តងគួរឬ ហង្សជាសម្លាញ់វានាំអញទៅទុកឯមហាស្រះឯណោះទេ នេះវាមកនាំគ្នាពោលថាហង្សពាំអញទៅស៊ុទីញ្ញ អណ្តើកគិតដូច្នោះហើយក៏កើតទោសានឹងពួកក្មេង ហាមាត់ទៀងនឹងជេរពួកក្មេងនោះ ឥមិត្តតែហាមាត់ទៀងកាលណា ក៏ធ្លាក់អំពីឈើបង្គងចុះមកដល់ផែនដីត្រូវនឹងដីទឹងដីថ្ម បែកស្កុកជាភាគ តួចភាគធំដល់នូវទិក្តមរណកាល កណ្តាលព្រះនគរពារាណសី បណ្តាក្មេងប្រុសស្រីក៏នាំគ្នាទៅសាច់អណ្តើកនោះយកទៅឲ្យម៉ែឪវាស្លបទិភោគហោង ។ ឯហង្សទាំងពីរកាលណាបើអណ្តើកទប្ងតមាត់ភ្លាត់ចាកឈើស្នែងធ្លាក់ស្លាប់ហើយ ក៏នាំគ្នាចោលឈើស្នែងនោះចេញចាកមាត់នៃអាត្មាពោលថា "អារអណ្តើកវាមិនដឹកល់នៅក្នុងឱវាទខ្លួនហាម បានជាដល់នូវទិក្តវិនាសយ៉ាងនេះ" ថាហើយក៏នាំគ្នាហើរទៅកាន់លំនៅនៃអាត្មាវិញហោង ។

ទៀងនេះ បានឥតដល់បុគ្គលអ្នកមិនសង្រួមបុខទ្វារ តឹមិនរក្សាមាត់ឲ្យល្អ បាននូវទិក្តទុក្ខទោសវិនាសប្រាណដូចអណ្តើកនោះឯងគួរចូលចិត្តចុះ ។

អនិច្ចាអណ្តើក អណ្តោតខ្វែកៗ បើកមាត់ដេរក្មេង និមិត្តហាមាត់ ភ្លាត់ចាកឈើស្នែង ធ្លាក់ស្លាប់ខ្លួនឯង ព្រោះមាត់រពីស ។

ចប់តម្រារពីសមាត់ជាគតិទី ៣៩។

ទៀងសត្វរាជសីហ៍ស្រឡាញ់មេគោ

មានសត្វរាជសីហ៍មួយ ដើរទៅឃើញមេគោរបស់នាយគោបាលម្នាក់ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់ស្នេហា ចូលទៅសេពកាមដោយមេគោរួចហើយក៏ចូលព្រៃ ។

អាការរាជសីហ៍សេពនឹងមេគោនោះមិនតែម្តងទៀយ សឹងចូលទៅសេពសព្វៗថ្ងៃ ឯមេគោទាំងឡាយ តាំងតែពីរាជសីហ៍ចូលកាល់ទៀយៗមក ក៏ស្គាំងស្គមទ្រុមមាឌ ហើយទាំងមានក្តីភ័តភ័យខ្លាចរាជសីហ៍នោះផង ឯទឹកដោះសោតក៏ចេញមិនបរិបូណ៌ដូចអំពីមុនៗទៀយ ។

នាយគោបាល កាលបើបានឃើញរាជសីហ៍ចូលកាល់មេគោ

ទាំងឡាយនបស់ខ្លួនតែសព្វៗថ្ងៃដរាបដល់មេគោទាំងឡាយ
ស្គាំងស្គមទ្រមមាឌ នឹងទឹតយកទឹកដោះពុំសូវបាន ដូចកាលមុនៗ
ដូច្នោះ ក៏នាំសេចក្តីនុ៎ះ ទៅដំរាបដល់មហាសេដ្ឋី ជានាយធំឲ្យ
ជ្រាបហេតុសព្វប្រការ មហាសេដ្ឋីក៏ប្រាប់ឲ្យនាយគោបាល
ប្រកបថ្នាំពិសពុល យកទៅលាបគូថលាបនមនៃមេគោទាំង
ឡាយនោះ ដើម្បីបំពុលរាជសីហ៍ក្នុងកាលដែលវាមកលិធនោម
លិធគូថមេគោនោះ។ឯង។

ឯនាយគោបាលក៏ចេញមកស្តថ្នាំពិស បានហើយក៏នាំទៅ
លាបកាយនៃមេគោ តាមពាក្យមហាសេដ្ឋីបង្គាប់នោះឯង។

ឯរាជសីហ៍នោះលុះពេលព្រឹកឡើង ក៏ចូលទៅក្នុងហ្វូងគោ
ដល់ហើយក៏ទៅប្រលោមស្នេហា តាំងលិធកាយលិធគូថនៃមេ
គោនោះឯង លុះពាល់ត្រូវថ្នាំពិសនោះកាលណា ក៏តឹតពុល
ជាលផ្សព្វផ្សាយប្រកាច់ដួលចុះ ដល់នូវមរណកាលកណ្តាលលហ្វូងគោនោះហោង។

សីហ៍អើយសីហ៍ ស្លាប់ព្រោះគូថគោ ដោយឥតប្រាជ្ញា
តិតស្វែងតែកាម តើតញ៉ាំមស្នេហា មិនពិចារណា ឲ្យយល់ខុស
ត្រូវ។ ខ្លួនជាសត្វព្រៃ ជាតិគោទីទែ ខុសពូជពង្សផៅ គួរឬ

ទៅធ្វើ អំពើជំទៀ លិធគោពាល់ត្រូវ ថ្នាំពិសពុលកប្រ័យ។

ចប់តម្រាបុគ្គលស៊ីឬលិធអាហារមិនពិចារណាជាគតិទី ៤០។

មានសត្វពាននមួយ អាស្រ័យនៅខាងបណ្ណសាលាអាស្រមនៃ
ព្រះមហាប្ញសីបរមពោធិសត្វ ស្វានោះជាសត្វឡេះឡោះ នពីស
ក្នុងការសេពកាម តែឃើញលោតទៅនក ហើយយកអង្គជាតិទា
ដាក់ក្នុងនន្ទត្រចៀក នន្ទច្រមុះនៃព្រះបរមពោធិសត្វ ធ្វើអាការ
ការលោកិយទៅតាមភាពពាលផ្សេងៗ។

ឯបរមពោធិសត្វបានយល់ស្វាធ្វើអាការដូច្នោះព្រះអង្គនឹងបាន
ប្រហានទុះទាត់ស្វានោះចេញ ក៏ឥតអង្គុមាន ព្រោះព្រះទ័យ
តាំងនៅក្នុងកិច្ចចំនើនឈានសមាធិគុណ ឯកិនិយាពាលនបៀត
បៀនធ្វើនូវអសទ្ធម្មជាផ្លូវមេថុននឹងសោតទ្វារ ឃានទ្វារ នៃ
ព្រះមហាឥសីបរមពោធិសត្វនោះតែនឿយៗ នៀងៗមក។

លុះនៅយូរមក មានកាលថ្ងៃមួយ ចៅពាននចេញទៅស្វែង
រកអាហារនឹងបនិភោគ បានទៅឃើញអណ្តើកខ្មៅ១ ហាមាត់
ដេកលក់នៅក្នុងទី១ ពាននជាសត្វពីស ក៏ចូលទៅហើយ ដាក់
អង្គជាតិខ្លួនទៅក្នុងមាត់អណ្តើក ធ្វើអសទ្ធម្មដោយទ្វារមាត់
អណ្តើកនោះឯង។

ឯអណ្តើកនោះ លុះភ្លាក់ដឹងខ្លួនហើយក៏ខាំសង្កត់អង្គជាតិស្វានោះ ខ្ជាប់ពុំលែងទេ្បីយឯពានរក៏ឈឺពេតទេ្បីងតាំងបើកមាត់អណ្តើកឲ្យហាក់បើកពុំបាន អណ្តើកក៏ទឹតតែខាំសង្កត់ចុះ ពានរនិយាយអង្វរនលួងលោមឲ្យអណ្តើកលែងដូចម្តេចៗ អណ្តើកក៏ពុំលែងទេ្បីយ ចៅពានរបានក្តីទុក្ខទៃទានាពន់ពេកណាស់ ទើបគិតថា ក្តីទុក្ខអញម្តងនេះជាទុក្ខធំបំផុតនឹងរកលោកអញ អ្នកឯណា ជាពេទ្យជួយបន្ទោបង់ទោគនេះយល់ពុំមាន មានតែព្រះឥសីសីលាទើបអាចជួយកែទោគនេះបាន គិតហើយចៅពានទឱ្យនកាយទ្រអណ្តើកដោយដៃទាំងពីរ ដើរទឱ្យនៗកំប្រោនប្រាណចូលទៅកាន់ទីឋាននៃព្រះបរមពោធិសត្វៗ បែរទៅយល់ពានរទ្រអណ្តើកមកដូច្នោះ ក៏ជ្រាបហេតុនោះមួយរំពេចថា អស្វានេះទាជាសត្វទពីស ធ្លាប់មកបៀតបៀនអញតែទេ្បីយៗ ឥឡូវនេះទៅត្រូវទៃលើមាត់អណ្តើកៗ កាលណានឹងអត់បានដូចអញគួរខាំផ្តាលយ៉ាងនេះមិនលែង គិតហើយព្រះឥសីក៏ត្រាស់សួរចំអកទៅកាន់ស្វានោះថា "ហែចៅក្របីអើយ ថ្ងៃនេះចៅស្វែងអាហារភោក្តាចៅបានផ្លែខ្នុរ ឬផ្លែធូរេនយកមកប្រគេនអាត្មាចៅក្របី? ។

ឯពានរឈឺនឹងអណ្តើក ទាមិតខាំខ្លាំងណាស់ក៏ធ្វើមុខជូរនខំទូលទៅថា " បពិត្រលោក ព្រះតាបសមានធម៌សប្បុរសប្រសើរអើយ ខ្ញុំព្រះករុណានេះបានឮវិក្តីទុក្ខទៃទានា តើតអំពីអណ្តើកទាខាំពូជឈឺស្ទើរនឹងស្លាប់ហើយ ព្រះគុណអើយ ជួយប្រោសមេត្តាបង្ហាមាត់អណ្តើក ឲ្យពូជខ្ញុំបានរបើកចេញអំពីមាត់អណ្តើកក្នុងគ្រានេះទៅ ឲ្យតែខ្ញុំបានរួចអំពីទុក្ខនេះហើយ ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំរាងចាលហើយ ខ្ញុំលែងប្រព្រឹត្តការអសទ្ធម្មតទៅទៀតហើយព្រះករុណា" ។

ឯព្រះបរមពោធិសត្វ បានឮស្វាពោលពាក្យដូច្នោះ ក៏មានព្រះហឫទ័យអាសូរកនុណា ទើបត្រាស់ទៅកាន់អណ្តើកនោះថា "ហែបាកច្បះអើយ ចៅឯងជាកសត្របគោត្រ ឯខាងចៅក្របីជាកណ្ហញ្ញគោត្រ គោត្រទាំងពីរក៏ពុំឆ្ងាយអំពីគ្នា ហេតុនោះចូរអាណិតមេត្តាអត់ទោសចៅក្របីនេះម្តងទៅចុះ ចូរលែងខាំអង្គជាតិចៅក្របីនេះទៅ ដោយគ្នាទទួលខុសហើយទទួលទាងចាលហើយ" ។ ឯអណ្តើកបានស្តាប់ពាក្យពោធិសត្វហើយ ក៏ហាមាត់បើកឲ្យស្វានោះរួចចាកក្តីទុក្ខក្នុងកាលនោះហោង ។

ចៅពានរបានរួចអំពីមាត់អណ្តើកហើយក៏តើតអៀនខ្មាស់

ពោធិសត្វ ទើបក្រាបសំពះពោធិសត្វហើយចេញចាកទីនោះ
ទៅនៅទី១ ឆ្ងាយអំពីអាស្រមបទមពោធិសត្វ ពុំបានមកបៀត
បៀនពោធិសត្វតទៅទៀតទេ្បីយ ចាប់ដើមពីថ្ងៃនោះ
ហោង ។

ទេ្បីងនិទាននេះ មានសេចក្តីពិស្តារនៅក្នុងគម្ពីរតិកនិបាតឯ
ណោះ ក្នុងតម្រានេះខ្ញុំបាទទាញមកសំដែងតែប៉ុណ្ណោះដោយ
សង្ខេប ទុកជាបែបបគតិដល់បុគ្គលអ្នកល្មោភក្នុង កិលេសកាម
ប្រព្រឹត្តការទៅក្នុងព្រង់ ដែលពុំមែនជាទ្វារមេថុនតាមធម្មតា
លោកិយ បានសេចក្តីក្តៅក្រហាយ ដូចនិទានចៅពានរដែលសំ
ដែងទុកមកនេះ អ្នកមានប្រាជ្ញាគួរពិចារណាទៅទៀតចុះ ។

ស្វាអើយចៅស្វា ចៅល្មោភតណ្ហា មិនថាទ្វារអ្វី ឃើញតែ
ចន្លោះ ទៅបោះបោលថ្មី ត្រូវកាឡកិណី លើមាត់អណ្តើក ។
កើតក្តៅក្រហាយ ខំខ្វេះកកាយ មិនដាយរបើក បង់កេរ្តិ៍បង់
ខ្មាស់ ផ្តាលព្រោះចិត្តចើក ទៅលេងអណ្តើក អន្តរធានខ្លួន ។

ចប់តម្រារពីសលិង្គ ជាគតិទី ៤១។

ចប់ភាគទី ៧ តែប៉ុណ្ណោះ។
